01347338

E405/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ៖ ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 11 / 2016
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ចំពោះមុខ៖ ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

កាលបរិច្ឆេទ៖: ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦
ភាសាដើម៖ ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

# សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹង ALEXANDER HINTON (2-TCE-88)

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងទទួលបានសំណើរបស់មេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង សុំឱ្យបំពេញកិច្ចស៊ើបសួរក្នុងគោលបំណងដើម្បីទទួលបានឯកសារមួយចំនួនដែលអ្នកជំនាញ Alexander Laban Hinton (2-TCE-88) បានសំអាងទៅលើនៅក្នុងការរៀបចំសរសេរសៀវភៅរបស់គាត់ដែលមានចំណងជើងថា *ហេតុអ្វីបានជាពួកគេសម្លាប់?* (*Why did they Kill?*)[1] ។ ឯកសារដែលមេធាវីការពារក្តី នួន ជា បានស្នើសុំនោះ គឺ (១) ការអង្កេតដែលលោក Hinton បានធ្វើឡើងនៅចន្លោះពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ១៩៩៥ រួមទាំងចម្លើយតបនានានៅក្នុងការអង្កេតនោះ (២) ខ្សែអាត់សំឡេងអំពីកិច្ចសម្ភាសន៍ដែលលោក Hinton (2-TCE-88) បានធ្វើឡើងនៅក្នុងការរៀបចំសរសេរសៀវភៅរបស់គាត់ ជាពិសេសខ្សែអាត់នៃការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗរបស់គាត់ ព្រមទាំងប្រតិចារឹកនៃកិច្ចសម្ភាសន៍ទាំងនោះ (៣) កំណត់ត្រារបស់លោក Hinton (2-TCE-88) នៅក្នុងអំឡុងការសិក្សាស្រាវជ្រាវរបស់គាត់ នៅក្នុងប្រទេសកម្ពុជា និង (៤) បញ្ជីលេខកូដដែលមានឈ្មោះមនុស្ស ហើយដែលនៅក្នុងសៀវភៅរបស់គាត់មានប្រើតែរហស្សនាមប៉ុណ្ណោះ ("បញ្ជីលេខកូដ") (ជារួមហៅថា "ឯកសារមូលដ្ឋាន")[2]។ មេធាវីការពារក្តី នួន ជា ក៏ស្នើសុំឱ្យផ្តល់ឱកាសដល់ភាគីក្នុងការធ្វើសេចក្តីសន្និដ្ឋានថាតើគួរទទួលយកឯកសារមូលដ្ឋានទាំងនេះធ្វើជាភស្តុតាងដែរ ឬទេ និងថាតើ គួរមានវិធានការអ្វីបន្ថែមទៀតដែរ ឬទេ[3]។

## ២. សារណា

២. មេធាវីការពារក្តី នួន ជា អះអាងថា ជាការចាំបាច់បំផុតដែលមេធាវីការពារក្តីត្រូវពិនិត្យមើលកំណត់ហេតុនៃកិច្ចសម្ភាសន៍របស់លោក Hinton (2-TCE-88) នៅក្នុងការរៀបចំសរសេរសៀវភៅរបស់គាត់ដែលមានចំណងជើងថា *ហេតុអ្វីបានជាពួកគេសម្លាប់?* និង អត្តសញ្ញាណនៃអ្នកផ្តល់ការ

---

[1] សំណើរបស់ នួន ជា សុំឱ្យបំពេញកិច្ចស៊ើបសួរ (សំណើសុំឯកសារ) ទាក់ទិននឹង Alexander Laban Hinton (2-TCE-88) ឯកសារ E405 ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦ ("សំណើ") កថាខណ្ឌ ១, ៤០។ លោក Hinton បានផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញនៅក្នុងសំណុំរឿង ០០២/០២ ចាប់ពីថ្ងៃទី ១៤ ដល់ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ (សូមមើល ឯកសារ E1/401.1, E1/402.1, E1/403.1, E1/404.1)។

[2] សំណើ កថាខណ្ឌ ២៥, ៤០។

[3] សំណើ កថាខណ្ឌ ៤០។

សម្ភាសន៍ទាំងនេះ ដើម្បីវាយតម្លៃអំពីភាពត្រឹមត្រូវនៃការអះអាងរបស់លោក Hinton និង ទម្ងន់ដែលត្រូវផ្តល់ទៅឱ្យភស្តុតាងរបស់គាត់[4]។ មេធាវីការពារក្តី នួន ជា កត់សម្គាល់ថា លោក Hinton (2-TCE-88) បានផ្តល់សក្ខីកម្មថា នៅក្នុងអំឡុងការធ្វើដំណើររបស់គាត់មកកាន់ប្រទេសកម្ពុជានៅមុនឆ្នាំ ២០០២ គាត់បានសម្ភាសន៍ ឬបាននិយាយទៅកាន់មនុស្សប្រមាណពី ១៥០ នាក់ ទៅ ២០០ នាក់ នៅកំពង់ចាម និង កំពង់សៀម តំបន់ ៤១ និង នៅភ្នំពេញ[5]។ មនុស្សដែលគាត់បានសម្ភាសន៍ទាំងនោះ រួមមាន អតីតកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ អ្នកជាប់ឃុំ អ្នកដែលត្រូវចោទប្រកាន់ថាជាអ្នកយាម ឬជាអ្នកធ្វើការនៅមន្ទីរសន្តិសុខ ស-២១ អ្នកភូមិ អ្នកកាសែត អ្នកធ្វើការផ្នែកសិទ្ធិមនុស្ស អ្នកនយោបាយ និង បុគ្គលមួយចំនួនទៀត[6]។ គាត់ក៏បានបញ្ជាក់ផងដែរថា គាត់មានខ្សែអាត់ថតសំឡេង ប្រតិចារឹក និង/ឬកំណត់ត្រានៃកិច្ចសម្ភាសន៍ និង ការស្រាវជ្រាវរបស់គាត់[7]។

៣. មេធាវីការពារក្តី នួន ជា អះអាងថា នៅក្នុងសៀវភៅរបស់គាត់ លោក Hinton (2-TCE-88) ពុំបានដាក់ឈ្មោះអ្នកដែលគាត់បានសម្ភាសន៍ឡើយ ហើយក៏ពុំមានការយោងនៅជើងទំព័រទៅដល់កិច្ចសម្ភាសន៍ណាមួយដែលគាត់បានធ្វើឡើងឡើយ[8]។ ផ្ទុយទៅវិញ គាត់ប្រើរហស្សនាម ឬយោងទៅមនុស្សទូទៅ។ នៅពេលសួរអំពីអត្តសញ្ញាណបុគ្គលមួយចំនួន រួមទាំងអ្នកផ្តល់ព័ត៌មានសំខាន់ៗ លោក Hinton (2-TCE-88) មិនអាចឆ្លើយតបបានទេ។ គាត់បានបញ្ជាក់ថា គាត់មិនអាចចាំឈ្មោះទាំងអស់បានទេ ដោយសារតែគាត់ប្រើបញ្ជីលេខកូដ ដែលគាត់ពុំបានយកមកជាមួយគាត់[9]។

៤. មេធាវីការពារក្តី នួន ជា អះអាងថា យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("តុលាការ ICTY") និង តុលាការព្រហ្មទណ្ឌអន្តរជាតិ ("តុលាការ ICC") តម្រូវឱ្យអ្នកជំនាញផ្តល់ព័ត៌មានគ្រប់គ្រាន់ទាក់ទិននឹងវិធីសាស្ត្រដែលបានប្រើ និង ប្រភពនានា ដែលយក

---

[4] សំណើ កថាខណ្ឌ ១, ២៤, ៣៨។

[5] សំណើ កថាខណ្ឌ ៤-៦, ២៨-២៩។

[6] សំណើ កថាខណ្ឌ ៤, ៦។

[7] សំណើ កថាខណ្ឌ ១០, ៣៩។

[8] សំណើ កថាខណ្ឌ ១១។

[9] សំណើ កថាខណ្ឌ ១២-១៣។

មកសំអាងនោះ និង អះអាងថា លោក Hinton (2-TCE-88) ពុំបានបំពេញលក្ខខណ្ឌនេះទេ[10]។ មេធាវីការពារក្តី នួន ជា កត់សម្គាល់បន្ថែមទៀតថា ប្រភពដែលអ្នកជំនាញយកមកប្រើប្រាស់ ចាំបាច់ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់ និង អាចពិនិត្យមើលបាន[11]។ មេធាវីការពារក្តី នួន ជា អះអាងថា ពុំមានព័ត៌មានទាល់តែសោះទាក់ទិននឹងយថាភាព និង ភាពគួរឱ្យជឿជាក់បាននៃភស្តុតាងរបស់លោក Hinton (2-TCE-88) ហើយក្រៅតែពីការលើកឡើងផ្ទាល់ខ្លួនរបស់គាត់នោះ ពុំមានភស្តុតាងដែលថា គាត់ពិតជាបានធ្វើការស្រាវជ្រាវដល់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា ឬ ពិតជាបានធ្វើការសម្ភាសន៍បុគ្គលទាំងនោះឡើយ[12]។

៥. មេធាវីការពារក្តី នួន ជា អះអាងថា ការពិនិត្យមើលឯកសារមូលដ្ឋានរបស់លោក Hinton (2-TCE-88) គឺជាការចាំបាច់ដើម្បីធ្វើការវាយតម្លៃអំពីភាពត្រឹមត្រូវនៃការអះអាងរបស់គាត់ ហើយថា ប្រសិនបើមិនបានពិនិត្យមើលសម្ភារៈទាំងនេះទេ មេធាវីការពារក្តី នួន ជា ពិតជាត្រូវបានរាំងមិនឱ្យជំទាស់ទៅនឹងមូលដ្ឋាននៃការធ្វើសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញហើយ[13]។ មេធាវីការពារក្តីអះអាងបន្ថែមទៀតថា សំណើសុំនេះមិនអាចធ្វើឡើងឱ្យបានលឿនជាងនេះបានឡើយ ដោយសារតែមេធាវីការពារក្តីសង្ឃឹមថានឹងយកព័ត៌មានពីលោក Hinton (2-TCE-88) នៅក្នុងអំឡុងពេលសួរដេញដោលរូបគាត់ ប៉ុន្តែអ្នកជំនាញរូបនេះមិនអាចផ្តល់ព័ត៌មានជាក់លាក់ទាក់ទិននឹងប្រភពរបស់គាត់នោះឡើយ[14]។

៦. មេធាវីការពារក្តី នួន ជា អះអាងថា អង្គជំនុំជម្រះសាលាដំបូងក៏ត្រូវបានរាំងមិនឱ្យធ្វើការវាយតម្លៃឱ្យបានត្រឹមត្រូវទៅលើភស្តុតាងរបស់អ្នកជំនាញផងដែរ ដោយគ្មានលទ្ធភាពពិនិត្យមើលឯកសារមូលដ្ឋានទាំងនោះ។ មេធាវីការពារក្តី នួន ជា ចង្អុលបង្ហាញអំពីសេចក្តីសម្រេចដាច់ដោយឡែកមួយរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធមិនទទួលយករបាយការណ៍របស់អង្គការឃ្លាំ-

---

[10] សំណើ កថាខណ្ឌ ២០-២៣ (និងឯកសារយោងនៅក្នុងនោះ) ៣១-៣២។

[11] សំណើ កថាខណ្ឌ ២០។

[12] សំណើ កថាខណ្ឌ ៣៤។

[13] សំណើ កថាខណ្ឌ ៣៦-៣៧។

[14] សំណើ កថាខណ្ឌ ២៧។

មើលសិទ្ធិមនុស្សធ្វើជាឯកសារភស្តុតាង ដោយសំអាង ក្នុងចំណោមហេតុផលផ្សេងៗទៀតថា ឯកសារយោងខ្លះមានលក្ខណៈស្រពិចស្រពិល និង ពុំបានបញ្ជាក់ពីបុគ្គលដែលត្រូវបានសម្ភាសន៍នោះ។ មេធាវីការពារក្តី នួន ជា លើកឡើងថា សំអាងហេតុរបស់អង្គជំនុំជម្រះនៅក្នុងសេចក្តីសម្រេចនោះ ត្រូវអនុវត្តចំពោះសៀវភៅ និង ភស្តុតាងរបស់លោក Hinton (2-TCE-88) ដូចគ្នា។ មេធាវីការពារក្តីអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់វិធាន ៩៣ នៃវិធានផ្ទៃក្នុងនៅក្នុងសំណុំរឿង ០០២/០១ ដើម្បីស្នើសុំឱ្យមានការផ្តល់ភស្តុតាងពីអ្នកជំនាញ ហើយថា វិធានការដូចគ្នានេះគួរយកមកអនុវត្ត[15]។ មេធាវីការពារក្តីសន្និដ្ឋានថា ការប្រមូល និង ការវិភាគទៅលើប្រភពនានាដែលលោក Hinton (2-TCE-88) បានប្រើប្រាស់នោះគឺជាប្រយោជន៍នៃយុត្តិធម៌ ដោយហេតុថា ព័ត៌មាននេះគឺជាមូលដ្ឋានក្នុងការវាយតម្លៃទៅលើសក្ខីកម្មរបស់គាត់[16]។

៧. សហព្រះរាជអាជ្ញាបានឆ្លើយតបថា សំណើនេះគួរត្រូវបានបដិសេធ ដោយសារតែជាសំណើមិនទាន់ពេលវេលា គ្រាន់តែជា "ការស្វែងរកព័ត៌មានដែលពុំមានមូលដ្ឋានច្បាស់លាស់" ជាការប៉ុនប៉ងដ៏យឺតពេលក្នុងការជំទាស់ទៅនឹងភាពជំនាញរបស់លោក Hinton (2-TCE-88) ហើយនឹងនាំឱ្យមានការពន្យារពេលកិច្ចដំណើរការនីតិវិធីដោយពុំត្រឹមត្រូវ។ ជម្រើសម្យ៉ាងទៀត សហព្រះរាជ-អាជ្ញាស្នើសុំឱ្យកោះហៅ 2-TCW-884 ឱ្យមកផ្តល់សក្ខីកម្ម[17]។

៨. សហព្រះរាជអាជ្ញាឆ្លើយតបថា មេធាវីការពារក្តី នួន ជា បានដឹងអំពីភស្តុតាងដែលបានស្នើឡើងរបស់លោក Hinton (2-TCE-88) យ៉ាងហោចណាស់តាំងពីខែ ឧសភា ឆ្នាំ ២០១៤ ហើយថា នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា លោក Hinton (2-TCE-88) នឹងផ្តល់សក្ខីកម្មចាប់ពីថ្ងៃទី ១៤ ដល់ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦។ លើសពីនេះទៀត សហព្រះរាជអាជ្ញាកត់សម្គាល់ថា មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យកោះហៅលោក Hinton

---

[15] សំណើ កថាខណ្ឌ ២៤ ដែលយោងលើសំណើសុំព័ត៌មានពាក់ព័ន្ធនឹងសេចក្តីសង្ខេបដែលអ្នកជំនាញ 2-TCE-33 បានរៀបចំ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E169។

[16] សំណើ កថាខណ្ឌ ៣៨។

[17] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំឱ្យបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹង Alexander Hinton (2-TCE-88) ឯកសារ E405/1 ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ("ចម្លើយតប") កថាខណ្ឌ ១។

(2-TCE-88) មកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ បើទោះបីជាចុងក្រោយគាត់មិនត្រូវបានកោះហៅនៅក្នុងរឿងក្តីនោះក៏ដោយ។ សៀវភៅរបស់លោក Hinton (2-TCE-88) ដែលអ្នកជំនាញពិពណ៌នាអំពីការប្រើប្រាស់ឯកសារមូលដ្ឋាននោះ ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ០០២ នៅក្នុងឆ្នាំ ២០១២ ផងដែរ។ យោងទៅលើសំអាងហេតុខាងលើ សហព្រះរាជអាជ្ញាអះអាងថា មេធាវីការពារក្តី នួន ជា មានឱកាសយ៉ាងច្រើនក្នុងការស្នើសុំឯកសារមូលដ្ឋាននេះ ហើយការខកខានមិនបានស្នើសុំកាលពីមុននេះ បង្ហាញឱ្យឃើញពីការខ្វះការយកចិត្តទុកដាក់ឱ្យបានខ្ពស់ ឬជាការប៉ុនប៉ងមួយដើម្បីពន្យារកិច្ចដំណើរការនីតិវិធី[18]។

៩. សហព្រះរាជអាជ្ញាអះអាងថា ការលើកឡើងរបស់មេធាវីការពារក្តី នួន ជា ដែលថា ខ្លួនមិនអាចដាក់សំណើសុំឱ្យបានលឿនជាងនេះ ដោយសារតែមេធាវីការពារក្តីសង្ឃឹមថានឹងអាចទទួលបានព័ត៌មានដែលនឹងស្នើសុំនៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់លោក Hinton (2-TCE-88) នោះ គឺមិនសមហេតុផលឡើយ។ សហព្រះរាជអាជ្ញាអះអាងថា ការស្នើសុំព័ត៌មាននេះមុនពេលការផ្តល់សក្ខីកម្មរបស់លោក Hinton (2-TCE-88) គឺជាការប្រាប់អ្នកជំនាញឱ្យដឹងជាមុនថាគាត់គួរតែយកសម្ភារៈនោះមកតាមខ្លួន ប្រសិនបើអាចធ្វើបាន[19]។

១០. សហព្រះរាជអាជ្ញាអះអាងថា សំណើនេះទូលំទូលាយពេក ហើយគឺជាការស្វែងរកព័ត៌មានដែលពុំមានមូលដ្ឋានច្បាស់លាស់។ លើសពីនេះទៀត សហព្រះរាជអាជ្ញាអះអាងថា មេធាវីការពារក្តី នួន ជា ផ្អែកទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY និង តុលាការ ICC ដែលមិនអាចយកមកអនុវត្តបានទេចំពោះកាលៈទេសៈនៃរឿងក្តីនេះ។ ទោះបីជារបាយការណ៍របស់អ្នកជំនាញនៅចំពោះមុខតុលាការទាំងនោះ ត្រូវបានរៀបចំឡើងដោយមានលក្ខណៈវិនិច្ឆ័យដែលមានការឯកភាពពីភាគីដែលស្នើសុំ ឬពីអង្គជំនុំជម្រះ សម្រាប់ករណីជាក់លាក់មួយ តែលោក Hinton (2-TCE-88) បានរៀបចំការសិក្សាស្រាវជ្រាវរបស់គាត់ដោយឯករាជ្យសម្រាប់ការសិក្សាថ្នាក់បណ្ឌិតរបស់គាត់ប៉ុណ្ណោះ[20]។

---

[18] ចម្លើយតប កថាខណ្ឌ ២-៤។

[19] ចម្លើយតប កថាខណ្ឌ ៥។

[20] ចម្លើយតប កថាខណ្ឌ ៦-៧។

លើសពីនេះទៀត សហព្រះរាជអាជ្ញាអះអាងថា គោលជំហរមិនច្បាស់លាស់របស់មេធាវីការពារក្តី នួន ជា ដែលថា មតិយោបល់របស់អ្នកជំនាញដែលផ្អែកលើប្រភពគ្មានឈ្មោះ មិនអាចយកមកសំអាងបាននោះ គឺមិនត្រឹមត្រូវទេ ពីព្រោះមេធាវីការពារក្តី នួន ជា ក៏មិនបានស្នើសុំប្រភពនានាពីអ្នកជំនាញផ្សេងៗទៀតដែលខ្លួនបានស្នើសុំឱ្យកោះហៅនោះដែរ ដូចជា Michael Vickery ជាដើម[21]។

១១. សហព្រះរាជអាជ្ញាអះអាងថា សំណើសុំនេះគឺការជាការប៉ុនប៉ងដែលធ្វើឡើងយឺតពេលក្នុងគោល-បំណងដើម្បីជំទាស់ទៅនឹងជំនាញរបស់លោក Hinton (2-TCE-88) ហើយថា ការអះអាងរបស់មេធាវីការពារក្តី នួន ជា ដែលថា ពុំមានភស្តុតាងបង្ហាញថា លោក Hinton (2-TCE-88) ពិតជាធ្លាប់មកដល់ប្រទេសកម្ពុជានោះ គឺពុំគួរឱ្យជឿជាក់បានឡើយ[22]។

១២. សហព្រះរាជអាជ្ញាក៏បានឆ្លើយតបថា មេធាវីការពារក្តី នួន ជា ពិតជាមិនត្រូវបានរារាំងមិនឱ្យជំទាស់ទៅនឹងមូលដ្ឋានដែលលោក Hinton (2-TCE-88) យកមកធ្វើជាសំអាងក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់គាត់នោះឡើយ ដោយសារតែមេធាវីការពារក្តីបានសួរដេញដោលយ៉ាងច្រើនទៅអ្នកជំនាញទាក់ទិននឹងកិច្ចការចុះស្រាវជ្រាវដល់មូលដ្ឋានរបស់គាត់ និង ការប្រើប្រាស់ឯកសារមូលដ្ឋាននៅក្នុងតុលាការ។ យោងតាមសហព្រះរាជអាជ្ញា មេធាវីការពារក្តី នួន ជា មិនបានកំណត់អត្ត-សញ្ញាណថាតើ អង្គហេតុណាខ្លះដែលខ្លួនមានបំណងជំទាស់នៅពេលនេះ និង មិនបានពន្យល់ថាតើហេតុអ្វីបានជាខ្លួនមិនអាចជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់លោក Hinton (2-TCE-88) ដោយផ្អែកលើភស្តុតាងផ្សេងៗទៀតនៅក្នុងសំណុំរឿង នៅពេលខ្លួនមានឱកាសធ្វើការជំទាស់នោះ[23]។

១៣. សហព្រះរាជអាជ្ញាកត់សម្គាល់ថា មុនពេលបញ្ចេញអត្តសញ្ញាណនៃប្រភពសម្ងាត់នោះ លោក Hinton (2-TCE-88) ត្រូវពិគ្រោះជាមួយនឹងសាកលវិទ្យាល័យរបស់គាត់ ទាក់ទងនឹងពិធីសារស្តីពីប្រភពឯកសារទាំងនោះ។ ដោយហេតុថា លោក Hinton (2-TCE-88) បានជួបនិយាយជាមួយ

---

[21] ចម្លើយតប កថាខណ្ឌ ៧-៨។

[22] ចម្លើយតប កថាខណ្ឌ ៩-១០។

[23] ចម្លើយតប កថាខណ្ឌ ១១។

មនុស្សយ៉ាងច្រើននោះកិច្ចការនេះនឹងជានីតិវិធីមួយដែលត្រូវការពេលវេលាច្រើន។ មានការបង្ហាញឱ្យឃើញផងដែរថា កិច្ចសម្ភាសន៍មួយចំនួនមានតែជាភាសាខ្មែរប៉ុណ្ណោះ ដែលនឹងតម្រូវឱ្យចំណាយពេលវេលាយូរសម្រាប់បកប្រែផងដែរ។ សរុបសេចក្ដីមក សហព្រះរាជអាជ្ញាអះអាងថា ប្រសិនបើយល់ព្រមតាមសំណើនេះ វានឹងធ្វើឱ្យមានការពន្យារកិច្ចដំណើរការនីតិវិធីដោយមិនចាំបាច់ និង រារាំងដល់កាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការធានានូវការជំនុំជម្រះមួយឱ្យបានឆាប់រហ័ស[24]។

១៤. ចុងក្រោយ សហព្រះរាជអាជ្ញាអះអាងថា មេធាវីការពារក្ដីបានបញ្ជាក់អំពីភាពច្បាស់លាស់ថា អ្នកផ្ដល់ព័ត៌មានសំខាន់របស់លោក Hinton (2-TCE-88)គឺជាសាក្សី 2-TCW-884។ មេធាវីការពារក្ដីខកខានមិនបានធ្វើការពន្យល់ថាតើហេតុអ្វីបានជាការស្នើសុំកោះហៅសាក្សី 2-TCW-884 ឱ្យចូលមកផ្ដល់សក្ខីកម្មនឹងមិនឆ្លើយតបទៅនឹងការអះអាងរបស់ខ្លួនដែលថា ពុំមានភស្តុតាងបង្ហាញថា លោក Hinton (2-TCE-88) បានធ្វើការសម្ភាសន៍បុគ្គលនានានោះ។ បើតាមសហព្រះរាជអាជ្ញា ការកោះហៅសាក្សី 2-TCW-884 ឱ្យមកផ្ដល់សក្ខីកម្ម គឺជាវិធានការសមស្របមួយផ្សេងទៀតចំពោះសំណើនេះ[25]។

១៥. ភាគីផ្សេងៗទៀតពុំបានឆ្លើយតបទៅនឹងសំណើនេះទេ។

## ៣. <u>ច្បាប់ជាធរមាន</u>

១៦. អនុលោមតាមវិធាន ៨៣ នៃវិធានផ្ទៃក្នុង ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះអាចបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា។ ភាពចាំបាច់នេះត្រូវតែសំអាងលើប្រយោជន៍នៃយុត្តិធម៌។ លើសពីនេះទៀត ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការបង្គាប់ឱ្យមានការស៊ើបសួរបន្ថែមត្រូវតែពិនិត្យនៅក្នុងបរិបទនៃក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ដែលធានាសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ និង

---

[24] ចម្លើយតប កថាខណ្ឌ ១២-១៣។

[25] ចម្លើយតប កថាខណ្ឌ ១, ១៤។

ឆាប់រហ័ស ហើយប្រធានអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការបដិសេធរាល់នីតិវិធីដែលនាំឱ្យមានការពន្យារពេលដល់ការជំនុំជម្រះ[26]។ ការសាកសួរបន្ថែមនេះអាចរួមមាន ការស្តាប់ចម្លើយសាក្សី ការស្នើសុំព័ត៌មាន ឬ ការឆែកឆេរ[27]។

## ៤. សំអាងហេតុ

១៧. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សំណើដែលមេធាវីការពារក្តី នួន ជា បានដាក់នោះ គឺជាសំណើយឺតពេល។ មេធាវីការពារក្តី នួន ជា បានដឹងថា សៀវភៅរបស់លោក Hinton (2-TCE-88) ផ្អែកទៅលើប្រភពឯកសារដើម និង មានឱកាសស្នើសុំឯកសារទាំងនេះ តាំងពីពេលមុន និងនៅក្នុងការត្រៀមរៀបចំសម្រាប់ការចោទសួរគាត់ម្តេះ ប៉ុន្តែ មេធាវីការពារក្តី ខកខានពុំបានបំពេញកិច្ចការនេះឡើយ។ ទាក់ទិននឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា (១) មេធាវីការពារក្តី នួន ជា ខ្លួនឯងផ្ទាល់បានស្នើសុំឱ្យកោះហៅលោក Hinton (2-TCE-88) មកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១។ (២) លោក Hinton (2-TCE-88) ត្រូវបានស្នើឡើងជាអ្នកជំនាញនៅក្នុងរឿងក្តីនេះ នៅក្នុងខែ ឧសភា ឆ្នាំ ២០១៤។ (៣) នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៦ ភាគីទទួលបានឱកាសដើម្បីធ្វើការកត់សម្គាល់ចំពោះអ្នកជំនាញនានាដែលបានស្នើឡើង ហើយមេធាវីការពារក្តី នួន ជា ពុំបានធ្វើការកត់សម្គាល់អ្វីឡើយ។ (៤) ភាគីទទួលបានដំណឹងនៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ថា លោក Hinton (2-TCE-88) នឹងត្រូវកោះហៅឱ្យមកផ្តល់សក្ខីកម្មនៅក្នុងខែ មីនា ឆ្នាំ ២០១៦។ (៥) លោក Hinton (2-TCE-88) ត្រូវបានតែងតាំងជាអ្នកជំនាញ នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦ និង (៦) លោក Hinton (2-TCE-88) បានផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ នៅថ្ងៃទី ១៤ ដល់ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦។ មេធាវីការពារក្តី នួន ជា គ្រាន់តែលើកឡើងថា "មេធាវីការពារក្តីសង្ឃឹមថានឹងអាចយកព័ត៌មានទាក់ទងនឹងអត្តសញ្ញាណ

---

[26] សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី, ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក Rob Lemkin ឯកសារ E294/1 ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១១។

[27] សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី, ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក Rob Lemkin ឯកសារ E294/1 ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១១។ សំណើសុំព័ត៌មានពាក់ព័ន្ធនឹង សេចក្តីសង្ខេបដែលអ្នកជំនាញ 2-TCE-33 បានរៀបចំ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E169 ទំព័រ ១។

នៃប្រភពរបស់លោក Hinton (2-TCE-88) នៅក្នុងអំឡុងពេលសួរដេញដោលគាត់នៅក្នុងសវនាការ"[28]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា យុទ្ធសាស្ត្របែបនេះគឺជាការបង្ហាញឱ្យឃើញនូវការខ្វះខាតការយកចិត្តទុកដាក់ដ៏ត្រឹមត្រូវរបស់មេធាវីការពារក្តី។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តី នួន ជា អាច និង គួរតែបានដាក់សំណើនេះឱ្យបានមុននេះតាំងពីយូរមកហើយ ប្រសិនបើខ្លួនយល់ឃើញថា សំណើនេះនឹងគាំទ្រយ៉ាងពិតប្រាកដដល់ផលប្រយោជន៍របស់កូនក្តីខ្លួននោះ។ អង្គជំនុំជម្រះយល់ឃើញថា យុត្តិកម្មរបស់មេធាវីការពារក្តី នួន ជា ចំពោះការខកខានមិនបានដាក់សំណើកាលពីមុននេះ មិនគួរឱ្យជឿជាក់បានឡើយ។

១៨. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វិធានការដែលមេធាវីការពារក្តី នួន ជា បានស្នើឡើងនេះនឹងនាំឱ្យមានការពន្យារពេលដោយមិនត្រឹមត្រូវនូវកិច្ចដំណើរការនីតិវិធីដែលត្រូវអនុវត្តឱ្យបានឆាប់រហ័ស និង ប្រកបដោយយុត្តិធម៌ ដូច្នេះហើយការស្នើឡើងនេះមិនស្ថិតនៅក្នុងប្រយោជន៍នៃយុត្តិធម៌ទេ។ ជារួម សំណើនេះមានលក្ខណៈទូលំទូលាយពេក ដោយស្នើសុំឯកសារមូលដ្ឋាននៃការស្រាវជ្រាវសំខាន់ៗទាំងអស់តែម្តង។ អង្គជំនុំជម្រះកាលពីមុនបានបដិសេធមិនបង្គាប់ឱ្យមានការបំពេញកិច្ចស៊ើបសួរឡើយ ក្នុងករណីដែលសំណើសុំគ្រាន់តែជាការស្វែងរកព័ត៌មានដែលពុំមានមូលដ្ឋានច្បាស់លាស់នោះ ដោយហេតុថា ការធ្វើបែបនេះវាពិតជាផ្ទុយទៅនឹងកាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការដឹកនាំការជំនុំជម្រះឱ្យបានឆាប់រហ័ស[29]។ នៅក្នុងករណីនេះ សំណើនេះសុំឱ្យផ្តល់ជូនមេធាវីការពារក្តីនូវឯកសារ និង សម្ភារៈជាច្រើនប្រភេទ ដែលទំនងធ្វើឱ្យមានការពន្យារពេលដោយសារតែចំនួនឯកសារដែលត្រូវបកប្រែ។

១៩. ទោះបីជាមេធាវីការពារក្តី នួន ជា កត់សម្គាល់យ៉ាងត្រឹមត្រូវថា អង្គជំនុំជម្រះបានស្នើសុំព័ត៌មានអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ពីបុគ្គលម្នាក់ដែលត្រូវបានស្នើឡើងឱ្យមកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញនៅក្នុងសំណុំរឿង ០០២/០១ ក៏ដោយ ក៏កាលៈទេសៈបច្ចុប្បន្ននេះគឺខុសគ្នា។

[28] សំណើ កថាខណ្ឌ ២៧។

[29] សូមមើល សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី, ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោកRob Lemkin ឯកសារ E294/1 ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ២៣-២៤។

នៅក្នុងរឿងក្តីនោះ អង្គជំនុំជម្រះត្រូវការឯកសារដែលត្រូវបានបង្ហាញអត្តសញ្ញាណច្បាស់លាស់។ លើសពីនេះទៀត វិធានការនេះត្រូវបានអនុវត្តឡើងយ៉ាងយូរមុនការផ្តល់សក្ខីកម្មរបស់បុគ្គលរូបនោះ ដែលពីដំបូងត្រូវបានអង្គជំនុំជម្រះសាលាដំបូងតែងតាំងជាអ្នកជំនាញ ប៉ុន្តែក្រោយមក ត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មក្នុងនាមត្រឹមតែជាសាក្សីប៉ុណ្ណោះ[30]។

២០. ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងគឺជាអ្នកវាយតម្លៃទៅលើតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់អ្នកជំនាញ ដោយពិចារណាទៅលើភស្តុតាងដែលបានផ្តល់ជូនពាក់ព័ន្ធនឹងប្រភពនានា និង វិធីសាស្ត្រដែលអ្នកជំនាញរូបនោះបានប្រើប្រាស់។ អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលើការខ្វះខាតព័ត៌មានបែបនេះ នៅក្នុងការវាយតម្លៃអំពីតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់អ្នកជំនាញ។

២១. ឥឡូវនេះ អង្គជំនុំជម្រះធ្វើការពិចារណាលើសំណើជាជម្រើសម្យ៉ាងទៀតរបស់សហព្រះរាជអាជ្ញាសុំឱ្យកោះហៅសាក្សី 2-TCW-884 មកផ្តល់សក្ខីកម្ម។ អង្គជំនុំជម្រះយល់ឃើញថា ការកំណត់អត្តសញ្ញាណសាក្សី 2-TCW-884 ដោយមេធាវីការពារក្តី នួន ជា ថាជាប្រភពសំខាន់មួយដែលលោក Hinton (2-TCE-88) បានយកមកប្រើប្រាស់នោះ គឺជាការទាយស្មាន។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា មិនចាំបាច់ត្រូវកោះហៅសាក្សីរូបនេះនៅពេលនេះទេ។ ទោះបីសំណើជាជម្រើសម្យ៉ាងទៀតត្រូវបានបដិសេធក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើសំណើដំបូងរបស់សហព្រះរាជអាជ្ញាសុំឱ្យកោះហៅសាក្សី 2-TCW-884 ឱ្យមកផ្តល់សក្ខីកម្មទៅលើបញ្ហាដទៃទៀតនោះ នៅមិនទាន់សម្រេចនៅឡើយទេ។

[30] សំណើសុំព័ត៌មានពាក់ព័ន្ធនឹងសេចក្តីសង្ខេបដែលអ្នកជំនាញ 2-TCE-33 បានរៀបចំ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E169។ សេចក្តីសម្រេចស្តីពីការជ្រើសរើសអ្នកជំនាញដែលមានរហស្សនាម 2-TCE-33 ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E283។ *សូមមើល ផងដែរ* សក្ខីកម្មរបស់អ្នកជំនាញ 2-TCE-33 ប្រតិចារឹកថ្ងៃទី ០៩, ១០, ១១, ១៥, ១៦, ១៧ និង ១៨ ខែ កក្កដា ឆ្នាំ ២០១៣។

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**បដិសេធ** សំណើសុំរបស់មេធាវីការពារក្តី នួន ជា។

**បដិសេធ** សំណើសុំជាជម្រើសម្យ៉ាងទៀតរបស់សហព្រះរាជអាជ្ញាឲ្យកោះហៅ 2-TCW-884 ធ្វើជាសាក្សី។

ភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

E.C.C.C * C.E.T.C
TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**